# *សិលាចារឹកថ្មីមកពីប្រាសាទបន្ទាយព្រាវ K.១២៣៣*

ប្រជាពលរដ្ឋបានរកឃើញនិងយកសិលាចារឹកនេះ ចេញមកពីប្រាសាទបន្ទាយព្រាវ ស្ថិតនៅក្នុងភូមិថ្មី ឃុំស្វាយចេក ស្រុកស្វាយចេក តាំងពីកំឡុងឆ្នាំ១៩៩៧ មកម្ល៉េះ។ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ រួមសហការជាមួយនគរបាលការពារបេតិកភណ្ឌ និងអាជ្ញាធរមូលដ្ឋាន បានចុះទៅទទួលសិលាចារឹកនេះពីប្រជាពលរដ្ឋរស់នៅក្នុងភូមិបែកចានចាស់ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មករក្សាទុកនៅសារមន្ទីរខេត្ត នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៩។

តាមរយៈឯកសាររបស់អ្នកស្រាវជ្រាវបារាំងមួយចំនួន យើងស្គាល់ប្រាសាទនេះមានឈ្មោះថា "បន្ទាយព្រាវ" (Bantéai Préau / Banteai Priau / Bantãy Prãv)។ អ្នកស្រុកតំបន់នោះ ហៅប្រាសាទនេះថា "ប្រាសាទបន្ទាយព្រាវ" "ប្រាសាទកំផែងព្រាវ" ឬហៅយ៉ាងសាមញ្ញថា "ប្រាសាទព្រាវ"។ ចំពោះពាក្យ "បន្ទាយ" មានន័យថាជា "កំពែង" គឺរបងព័ទ្ធជុំវិញទីធ្លាអ្វីមួយ អាចជាប្រាសាទ, ព្រះរាជវាំង, រាជធានី, ក្រុងផ្សេងៗ ឬភូមិលំនៅជាដើម។ បន្ទាយឬកំពែងខ្លះធ្វើពីឈើ, ខ្លះធ្វើពីដី, ខ្លះធ្វើពីឥដ្ឋ, ខ្លះធ្វើពីថ្មបាយក្រៀម និងខ្លះទៀតធ្វើពីថ្មភក់ក៏មាន។ន័យដើមរបស់ពាក្យ "បន្ទាយ" គឺសំដៅថារបងឬកំពែង តែការហៅជាទូទៅក្លាយជាសំដៅរួមទាំងអ្វីៗដែលនៅក្នុងរបង ឬកំពែងទាំងមូលនោះតែម្តង។[១] ដោយសារប្រាសាទនេះមានកំពែង (អ្នកស្រុកហៅថាកំផែង) ឬបន្ទាយធ្វើអំពីថ្មបាយក្រៀមព័ទ្ធជុំវិញ ទើបនាំពួកគាត់ហៅឈ្មោះថា "បន្ទាយ ឬ កំផែងព្រាវ"។ ប្រាសាទនេះ ជាប្រាសាទសំខាន់មួយនៅតំបន់ស្វាយចេក[២] ព្រោះជាប្រាសាទដែលមានទំហំធំជាងប្រាសាទផ្សេងៗក្នុងតំបន់នេះ និងស្ថិតនៅខាងលិចឈៀងពាយ័ព្យទីរួមស្រុកស្វាយចេក មានចម្ងាយប្រហែលជា៨គីឡូម៉ែត្រ។

អត្ថបទចារឹកនេះ ចារនៅលើមេទ្វារថ្មព័ណ៌ផ្កាឈូក មានកម្ពស់ប្រវែង ១០៥,៥ស.ម. បន្ទារ២៥ស.ម. និងកម្រាស់១២ស.ម.។ អត្ថបទនេះចារជាភាសាខ្មែរបុរាណមានចំនួន៨បន្ទាត់ និងមានចុះកាលបរិច្ឆេទចំនួនពីរគឺ ឆ្នាំ៩២៩ មហាសករាជ និងឆ្នាំ៩២៧ មហាសក

---

[១] ព្រាប ចាន់ម៉ារ៉ា, ២០១២, ទំ. ១៦។

[២] Aymonier, 1901

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

ពជ។ ផ្ទាំងថ្មចារឹកនេះ សាច់ថ្មមានគ្រាប់ខ្សាច់ធំដែលងាយសឹករបេះ នាំឱ្យផ្ទៃថ្មពុំរៀបស្មើ ដាច់អក្សរដោយអន្ទើ និងកន្ទែងខ្លះពិបាកផ្ទាមសំណៅផ្ចិតៗ យ៉ាងនេះក្តី បើពិនិត្យមើលតាមទម្រង់អក្សរមានលក្ខណៈល្អស្អាតមួយបែបៗ សញ្ញាគោមូត្រចាប់ផ្តើមអត្ថបទស្អាតពិសេសម្យ៉ាងដែលកម្រនឹងឃើញមាន (៚)។

អត្ថបទចាប់ផ្តើមចារដោយឃ្លាកាត់ខ្លីៗ ខុសពីទម្រង់ដែលឃើញមានជាទូទៅ។ នៅបន្ទាត់ទី១ ពុំមានប្រាប់ពាក្យ "ឝក" បន្ទាប់ពីតួលេខដែលជាឆ្នាំមហាសករាជឡើយ។ ចំណែកឯឋានន្តរនាមមន្ត្រី ក៏ពុំមានដាក់នៅខាងដើមឈ្មោះដែរ។ចាប់ពីបន្ទាត់ទី៣ ត្រង់កាលបរិច្ឆេទមក ទើបអត្ថបទចារឹកឃ្លាឃ្លោងជម្មតាដូចដែលតែងជួបប្រទះក្នុងសិលាចារឹកនានា។ អត្ថបទនេះហាក់ចារឡើងដោយបន្ទាន់ ឯមនុស្សនៅជំនាន់នោះបានដឹងអំពីរឿងរ៉ាវហេតុការណ៍ដែលកើតឡើង ទើបអត្ថបទនេះចារឡើងខ្លីៗបែបនេះ ។

អត្ថបទនេះនិយាយអំពីដីភូមិបុកោង និងចន្ទ្រក្សេត្រ ដែលត្រូវថ្វាយដល់ប្រាសាទនៅឯត្បូងរមាំងក្នុងឆ្នាំ៩៤៩ នៃមហាសករាជ(១០២៧គ.ស.) និងរំលឹកអំពីអ្នកបម្រើប្រុសម្នាក់ឈ្មោះកន្សូរដែលចាញ់ក្តីវាបពល ហើយត្រូវឱ្យយកទៅបម្រើនៅឯប្រាសាទសិវលិង្គ។ ចុងក្រោយជាបញ្ជីឈ្មោះខ្ញុំបម្រើប្រុស៩នាក់(រាប់ទាំងកន្សូរ)។ សិលាចារឹកនេះ ជាសេចក្តីបំពេញបន្ថែមលើសិលាចារឹក K.២២១ និង K.២២២ លើករណីថ្វាយខ្ញុំទៅប្រាសាទសិវលិង្គ។

**អំណានជាអក្សរខ្មែរទំនើប**

១- ៚ ៩៤៩បន្ទូលតនរបតិន្ទ្រវម៌្មស្រុក្ឫ(កោ)ងចន្ទ្រក្សេត្រ

២- តិអញ្ញឹឱយតវ្រះនោះអាយថ្បូងម៌្មាងទហអ្នកទោសង្គោ

៣- លកំបិឱយិ ± ៩៤៧គក្កនុ(វា)បិវលតឱយិឃោកន្សូរ

៤- តវ្រះកម្រតេងអញ្ញគ្រីនរបតិន្ទ្រវម៌្មកន្សូរថ្វេប្រ

៥- គ[-ូា]វ្យវហារចញ្ញតវាបវលទេបិឱយតវ្រះទេបិ

៦- ទៅ(និ)វេទនវ្រះមន្ទូលប្រសិទ្ធិតវ្រះ[ស្តេង]គិវលិង្គពោះហ

៧- [កាល]វ្រះសភាំឃោកំវិតិឃោកន្សោតឃោវ្រាមឃោ

៨- ថ្ប៉ុកឃោកន្សូរឃោកបិតឃោផ្លំឃោថ្កោឃោកន្ទេង

អត្ថបទដោយៈ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

## សេចក្ដីប្រែសម្រួល

(១-៣) (នាឆ្នាំ)៩៤៩(នៃមហាសករាជ មានព្រះរាជ)បន្ទូលដល់(ព្រះគម្ដែងអញស្រី) នរបតិន្ទ្រវម៌្ម(អំពី)ស្រុកបុកោង(និង)ចន្ទ្រក្សេត្រ ដែលអញខ្ញុំថ្វាយដល់ព្រះនៅឯត្បូងរមាំង។ ទោះ(មាន)អ្នក(ណា)ទៅសង់គោល(ព្រំដីនោះយក ក៏)កុំគប្បីឱ្យ(ឡើយ)។

(៣-៨) (នាឆ្នាំ)៩៤៧នៃមហាសករាជ (ឆ្នាំ១០២៥គ.ស.) វាបពលដែលថ្វាយឃោកន្សូរ ដល់ព្រះគម្ដែងអញស្រីនរបតិន្ទ្រវម៌្ម(នោះ) កន្សូរធ្វើ....ប្ដឹងចាញ់វាបពល ទើបថ្វាយ (កន្សូរ) ដល់ព្រះ (បន្ទាប់មក) ទើបទៅទូលថ្វាយ (ព្រះមហាក្សត្រទ្រង់មាន) ព្រះបន្ទូលឱ្យសិទ្ធិ (គ្រប់គ្រងកន្សូរ)ដល់ព្រះស្ដេងសិវលិង្គដូចកាល(កាត់ក្ដីនៅ)ព្រះសភា។ (ខ្ញុំបម្រើថ្វាយដល់ព្រះស្ដេងសិវលិង្គមាន) ឃោកំរិត ឃោកន្សោត ឃោវ្រម ឃោថ្មៀក ឃោកន្សូរ ឃោកំបិត ឃោផ្អែម ឃោថ្កោ និងឃោកន្ទេង។

## វាក្យសព្ទ

**កំបិ** កុំបី ។

**ឃោ** ន. (សំ. ឃោដ) អ្នកបម្រើប្រុសវ័យពេញកម្លាំង។

**ចញ៌** កិ. ចាញ់។

**ត្បូងម្រាំង** ន. ក្បាលរមាំង, ទីកន្លែងឈ្មោះ ត្បូងរមាំង។

**ទហ** ទោះ។

**ទេបិ** ទើប។

**ទោ** ទៅ។

**ប្រសិទ្ធិ** កិ. ផ្ដល់សិទ្ធិឱ្យ។

**មន្ទូល** (< មនិ + ទូល) ទូល ទូលថ្វាយ។

**វាប** ន. ឋានន្តរនាមមន្ត្រីសម័យអង្គរ។

**វាបវល** ន. វាបពល ។ វាបទទួលបន្ទុកកងពល។

**វ្យវហារ** ន. ការកាត់ក្ដី, ដំណើរការក្ដី, បណ្ដឹង។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

**វ្រះស្តេង៑** ន. ព្រះស្តែង, ក្នុងសិលាចារឹកនេះសំដៅដល់ព្រាហ្មណ៍ជាអធិការប្រាសាទសិវលិង្គ។ ឧ. វ្រះស្តេង៑គិវលិង្គ = ព្រះស្តែងប្រាសាទសិវលិង្គ។

**វ្រះសភា** ន. ព្រះសភា តុលាការ។ ពាក្យ "សភា" សំដៅដល់ទីជំនុំ ទីកាត់ឬវិនិច្ឆ័យក្តី។ "ព្រះសភា" សំដៅដល់ទីសម្រាប់កាត់ក្តីផង និងអ្នកកាត់ក្តីផង ដូច្នេះទើបពាក្យ "សភា" ក្លាយទៅជា "សុភា" ហៅសំដៅដល់តួអង្គសត្វទន្សាយដែលតែងតែដើរតួជាអ្នកកាត់សេចក្តីណាមួយ ក្នុងរឿងព្រេង។

**សង្គោល** (< សង៑ + គោល) សង់គោលព្រំដី បោះបង្គោលព្រំដី។

**អញ្** ខ្ញុំ, ជាពាក្យហៅខ្លួនឯងទៅកាន់មនុស្សគ្រប់ឋានៈ។ បើហៅខ្លួនឯងចំពោះព្រះ ទេពតា ឬព្រះមហាក្សត្រ បុរាណតែងប្រើ "អញខ្ញុំ"។

នៅក្នុងអត្ថបទក្រោយ យើងនឹងពិភាក្សាអំពីស្ថាននាម "ត្បូងរមាំង" តាមរយៈភស្តុតាងសិលាចារឹក។

# បញ្ជីរូបភាព



វត្ថុសិល្បៈជាគ្រឿងលម្អប្រាសាទបន្ទាយព្រាវ (ដោយៈ ហ៊ុន ឈុនតេង)



រូបថតសិលាចារឹកមកពីប្រាសាទបន្ទាយព្រាវ (ដោយៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង


សំណៅផ្តិតសិលាចារឹកបន្ទាយព្រាវ (ដោយៈ ហ៊ុន ឈុនតេង)

## ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

(២០១២). ពាក្យប្រើចំពោះសំណង់បុរាណនិងក្បាច់លម្អ, (ហនុមានទេសចរណ៍), ភ្នំពេញ

Aymonier, E.

(1901). *Le Cambodge*, Vol. II. EFEO.


អត្ថបទដោយៈ ហ៊ុន ឈុនតេង